ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ..២១៣..សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៥៦៣ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០២៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញសេចក្តីសម្រេចលេខ ០៧ សសរ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០២៤ ស្តីពីការដាក់ឱ្យអនុវត្តកម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ ឆ្នាំ ២០២៤
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**ប្រការ១**.-

ត្រូវបានបង្កើត «**ក្រុមការងារជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ**» ក្រោមឆ័ត្រគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានសមាសភាព ដូចខាងក្រោម៖

១. ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធាន

| | | |
|---|---|---|
| ២. ឯកឧត្តមបណ្ឌិត **ផាន់ ផល្លា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាអគ្គលេខាធិការនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. ឯកឧត្តម **ពេជ្រ សម្បត្តិ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. ឯកឧត្តម **យុន ហោច** | អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា | អនុប្រធាន |
| ៥. ឯកឧត្តម **តឹកវ៉ែត សំរេច** | រដ្ឋលេខាធិការប្រចាំការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | សមាជិក |
| ៦. ឯកឧត្តម **ជីវ សុខហាក់** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៧. ឯកឧត្តម **នី ផល្លី** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៨. ឯកឧត្តម **សុខ សុភ័ក្ត្រ** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩. ឯកឧត្តម **ជាវ អានសាន** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ | សមាជិក |
| ១០. ឯកឧត្តម **នូ សុវត្ថិ** | រដ្ឋលេខាធិការក្រសួងសាធារណការ និង ដឹកជញ្ជូន | សមាជិក |
| ១១. ឯកឧត្តម **ផាន់ ចាន់ធុល** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១២. ឯកឧត្តម **ជួប មិត្តថេរឫទ្ធិ** | អនុរដ្ឋលេខាធិការក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៣. ឯកឧត្តម **សួន គារិទ្ធ** | អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |
| ១៤. លោក **ឡុច ឌីម៉ង់** | អភិបាលរងនៃគណៈអភិបាលខេត្តព្រះសីហនុ | សមាជិក |
| ១៥. លោក **ឯម គាព** | អភិបាលរងនៃគណៈអភិបាលខេត្តព្រះសីហនុ | សមាជិក |
| ១៦. ឯកឧត្តម **បេងហុង សុជាតិខេមរ៉ូ** | អគ្គនាយកនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | សមាជិក |
| ១៧. ឯកឧត្តម **យ៉ម ផារ៉ូត** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ | សមាជិក |
| ១៨. ឯកឧត្តម **ហូ ស៊ីវយ៉ុង** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គ-នាយកដ្ឋានសេវាពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៩. ឯកឧត្តម **ខ៊ែត វិបុល** | អគ្គនាយកនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ | សមាជិក |
| ២០. ឯកឧត្តម **សឿន ម៉ិនលី** | អគ្គនាយកនៃក្រសួងសាធារណការ និង ដឹកជញ្ជូន | សមាជិក |
| ២១. ឯកឧត្តម **សូស ប្រាថ្នា** | អគ្គនាយកនៃក្រសួងមហាផ្ទៃ | សមាជិក |
| ២២. លោក **ថង សាម៉ុន** | អគ្គនាយករងនៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២៣. លោក **ស៊ុ គីមច្រើទ្ធា** | ប្រធាននាយកដ្ឋាននៃក្រសួងទេសចរណ៍ | សមាជិក |

| | | | |
|---|---|---|---|
| ២៤. ឯកឧត្តម **ខា ភុកហុង** | ប្រធានលេខាធិការដ្ឋានក្រុមការងារបច្ចេកទេសអន្តរក្រសួង សម្របសម្រួលការរៀបចំផែនការមេ ដើម្បីអភិវឌ្ឍ ខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង | សមាជិក |
| ២៥. ឯកឧត្តម **រ័ត្ន មុនី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ២៦. លោក **ម៉ិន ឌីម** | ប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា | សមាជិក |
| ២៧. លោក **ត្រាំង ខៀវ** | អនុប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ២៨. លោក **សុខ កុសល** | អនុប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ២៩. លោក **សំ សុវណ្ណារិទ្ធ** | ប្រធានសាខាគយ និង រដ្ឋាករខេត្តព្រះសីហនុ | សមាជិក |
| ៣០. លោក **លី ម៉េងឃាង** | ប្រធានការិយាល័យនៃអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា | សមាជិក ។ |

**ប្រការ២.-**

ក្រុមការងារជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ មានភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំ, សម្របសម្រួល និង អនុវត្ត "កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ ឆ្នាំ ២០២៤" រួមទាំងវិធានការដោះស្រាយគម្រោងវិនិយោគជាប់គាំងក្នុងខេត្តព្រះសីហនុ ដោយដើរតួនាទីជា "ច្រកចេញចូលតែមួយ" ដែលមានសិទ្ធិពិនិត្យ, សម្រេច និង ផ្តល់លិខិតអនុញ្ញាត ឬ អាជ្ញាបណ្ណនានា ជាកញ្ចប់ទៅលើគម្រោងវិនិយោគ និង សកម្មភាពធុរកិច្ច
- រៀបចំឯកសារចាំបាច់នានា និង នីតិវិធីអនុវត្តការងាររបស់ក្រុមការងារ និង ធ្វើកិច្ចសហការល្អ ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ
- ធ្វើការផ្សព្វផ្សាយជាសាធារណៈនូវកម្មវិធីពិសេសឱ្យបានទូលំទូលាយ, ធ្វើការពន្យល់ឱ្យបានច្បាស់ និង ត្រឹមត្រូវ, និង ផ្តល់សេវាបដិសណ្ឋារកិច្ច និង កិច្ចសហការល្អដល់វិនិយោគិន និង ធុរជន, ទាំងក្នុងប្រទេស និង ក្រៅប្រទេស
- ដាក់ចេញកម្មវិធីពង្រឹងសមត្ថភាពដល់ថ្នាក់ដឹកនាំ និង មន្ត្រីជំនាញ ព្រមទាំងអ្នកពាក់ព័ន្ធ ដោយផ្តោតលើការបំពេញភារកិច្ច, ការសម្របសម្រួល, ការផ្តល់សេវាដល់វិនិយោគិន និង ធុរជន, ការរៀបចំគម្រោង និង ការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ ដើម្បីផ្តល់សេវា និង អនុវត្តការងារ ប្រកបដោយគណនេយ្យភាព, តម្លាភាព និង ប្រសិទ្ធភាព
- ពិនិត្យ, វាយតម្លៃ និង ផ្តល់ការអនុម័តលើគម្រោងវិនិយោគ និង សកម្មភាពធុរកិច្ច សម្រាប់ទទួល-បាននូវការលើកទឹកចិត្ត និង ការអនុគ្រោះនានាពីរាជរដ្ឋាភិបាល ដែលស្ថិតនៅក្រោមវិសាលភាពនៃកម្មវិធីពិសេស
- ពិនិត្យ និង ស្នើសុំដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តចាំបាច់នានា តាមរយៈគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- រៀបចំ និង អនុវត្តផែនការសកម្មភាព និង ក្របខណ្ឌតាមដានត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តកម្មវិធីពិសេស

- ធ្វើការតាមដាន និង វាយតម្លៃការអនុវត្តកម្មវិធីពិសេសនេះ ដើម្បីដោះស្រាយបញ្ហាប្រឈម, ដាក់ចេញវិធានការកែតម្រូវ, វាស់វែងពីការខិតខំប្រឹងប្រែង និង វាយតម្លៃប្រសិទ្ធភាព និង លទ្ធផលនៃការអនុវត្តកម្មវិធីពិសេសនេះ
- រៀបចំរបាយការណ៍ ៣ ខែម្តង ជូនរាជរដ្ឋាភិបាល តាមរយៈគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍វាយតម្លៃការអនុវត្តកម្មវិធីពិសេសនេះជូនរាជរដ្ឋាភិបាល តាមរយៈគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- អនុវត្តនូវកិច្ចការ ឬបំពេញភារកិច្ចដទៃទៀត តាមការសម្រេចរបស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ តាមការសម្រេចរបស់ប្រមុខរាជរដ្ឋាភិបាល តាមរយៈគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ៣**.-

ក្រុមការងារជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ មានធនធានហិរញ្ញវត្ថុក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ក្រុមការងារជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ មានសិទ្ធិប្រើប្រាស់ត្រាក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់បំពេញភារកិច្ច ទាំងតាមទម្រង់ច្បាប់ដើម និង តាមប្រព័ន្ធអេឡិកត្រូនិក ។

**ប្រការ៤**.-

ក្រុមការងារជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ មានសិទ្ធិអញ្ជើញតំណាងក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដែលទទួលបានប្រតិភូកម្ម ឬ មានសិទ្ធិសម្រេច ក្នុងនាមប្រធានក្រសួងស្ថាប័ន តាមការចាំបាច់ ដើម្បីចូលរួមអនុវត្តកម្មវិធីពិសេស ។

ក្រុមការងារជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ មានសិទ្ធិអញ្ជើញស្ថាប័នស្រាវជ្រាវ វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និង ជំនាញការ ដើម្បីផ្តល់ព័ត៌មាន និង យោបល់នានា សម្រាប់គោលបំណងសិក្សាស្រាវជ្រាវ និង រៀបចំគម្រោង ដែលស្ថិតក្រោមវិសាលភាពនៃកម្មវិធីពិសេស ។

ប្រធានក្រុមការងារជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ ទទួលខុសត្រូវរួមក្នុងការដឹកនាំក្រុមការងារ និង ដឹកនាំកិច្ចប្រជុំ ។ ប្រធានអាចចាត់តាំងអនុប្រធាន ឬ សមាជិកក្រុមការងារ ដឹកនាំការងារជំនួសក្នុងករណីចាំបាច់ ឬ ប្រធានអវត្តមាន ។

**ប្រការ៥**.-

ក្រុមការងារជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ មានលេខាធិការដ្ឋានមួយជាសេនាធិការ ។ លេខាធិការដ្ឋាននេះ មានសមាសភាពដូចខាងក្រោម៖

១. ឯកឧត្តម **អ៊ឹម សុខធី** អគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធាន

២. លោក **ស៊ឹម ពិសិដ្ឋ** អនុប្រធានលេខាធិការដ្ឋាននៃក្រុមការងារបច្ចេកទេសអន្តរក្រសួង សម្របសម្រួលការរៀបចំផែនការមេ ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុ ទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង — អនុប្រធាន

៣. លោក **ផាន់ ផេត** អគ្គនាយករងនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ — អនុប្រធាន

៤. លោក **ណុំ ស៊ីនិត** អគ្គនាយករងនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ — សមាជិក

៥. លោក **ហាម គីមឆេង** ប្រធានស្តីទីនាយកដ្ឋានវិភាគគម្រោង និង ការលើកទឹកចិត្ត នៃគណៈកម្មាធិការវិនិយោគកម្ពុជា — សមាជិក

៦. លោក **ជា គៀត** ប្រធានស្តីទីនាយកដ្ឋានទំនាក់ទំនងសាធារណៈ និង ការជំរុញគម្រោងវិនិយោគឯកជននៃគណៈកម្មាធិការវិនិយោគកម្ពុជា — សមាជិក

៧. លោក **ចេន រ៉េត** នាយករងរដ្ឋបាលនៃរដ្ឋបាលខេត្តព្រះសីហនុ — សមាជិក

៨. លោក **ឃាង តារម្យ** នាយកទីចាត់ការផែនការ និងវិនិយោគនៃរដ្ឋបាលខេត្តព្រះសីហនុ — សមាជិក

៩. លោក **ម៉ក់ ទិចិត្រសក្កដា** ប្រធាននាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ — សមាជិក

១០. លោក **សុត គីមសុន** ប្រធានការិយាល័យនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ — សមាជិក

១១. លោក **ម៉េង បូរ័ត្ន** អនុប្រធានការិយាល័យនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ — សមាជិក

១២. លោកស្រី **អេន ភក្តិដ្ឋា** ជំនួយការសាខាគយ និង រដ្ឋាករខេត្តព្រះសីហនុ — សមាជិក

១៣. លោក **អ៊ុន តេជៈបញ្ញា** មន្ត្រីនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ — សមាជិក

១៤. លោក **បេ ម៉េងអ៊ី** មន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារ — សមាជិក

១៥. លោក **សូ គានហ៊ុយ** សេដ្ឋវិទូនៃអគ្គនាយកដ្ឋានគោលនយោបាយ — សមាជិក ។

**ប្រការ៦.-**

លេខាធិការដ្ឋានក្រុមការងារជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ ដើរតួនាទីសម្របសម្រួលផ្នែករដ្ឋបាលទាំងអស់ និង មានការិយាល័យនៅខេត្តព្រះសីហនុ និង រាជធានីភ្នំពេញ តាមការចាំបាច់ ។

លេខាធិការដ្ឋាននេះ មានភារកិច្ចដូចខាងក្រោម ៖

- ផ្តល់សេវាគាំទ្រ និង បំពេញការងារ សម្រាប់ប្រក្រតីភាពនៃកិច្ចដំណើរការប្រចាំថ្ងៃ របស់ក្រុមការងារ
- សម្របសម្រួលកិច្ចទំនាក់ទំនងសាធារណៈ ធ្វើការផ្សព្វផ្សាយ ប្រឹក្សាយោបល់ និង ធ្វើបដិសណ្ឋារកិច្ចដល់វិនិយោគិន ធុរជន និង អ្នកផ្សេងទៀតដែលមានការពាក់ព័ន្ធ
- ពិនិត្យ វិភាគ និង លើកយោបល់ជូនក្រុមការងារពិនិត្យសម្រេច ព្រមទាំងសិក្សា និង ប្រមូលធាតុចូលសម្រាប់ការបំពេញភារកិច្ចរបស់ក្រុមការងារ
- រៀបចំផែនការសកម្មភាព និង ធ្វើការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តភារកិច្ច ព្រមទាំងរៀបចំរបាយការណ៍វឌ្ឍនភាពការងារ
- បំពេញភារកិច្ចដទៃទៀតតាមការសម្រេចរបស់ប្រធានក្រុមការងារ ។

**ប្រការ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ និង ប្រការ ៥ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

ថ្ងៃ សុក្រ ១រោច ខែ ស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ខែ សីហា ឆ្នាំ ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ